ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ.១៤.ណ..ស.ខ.ស

សេចក្តីណែនាំរបស់ក្រសួងសុខាភិបាល
ស្តីពី
ការការពារការចម្លងជំងឺកូវីដ-១៩ និងការពុលចំណីអាហារ
ក្នុងអំឡុងពិធីបុណ្យភ្ជាន់បិណ្ឌ និងភ្ជុំបិណ្ឌ

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា ដោយផ្អែកលើស្ថានភាពនៃការចម្លងវីរុសកូវីដ-១៩ នៅលើបណ្តាប្រទេសលើសកលលោក និងនៅក្នុងតំបន់ មិនទាន់មានការធូរស្បើយហើយ កំណើននៃការចម្លងវីរុសកូវីដ-១៩ និងការស្លាប់ដោយសារជំងឺនេះ នៅតែបន្តមានខ្ពស់នៅឡើយ បើទោះបីជាប្រទេសកម្ពុជា មិនទាន់មានការចម្លងវីរុសកូវីដ-១៩ នៅក្នុងសហគមន៍នៅឡើយក៏ដោយ ក៏ជំងឺដ៏កាចសាហាវនេះ នៅតែជាការគំរាមកំហែងសុខភាពសាធារណៈ ហើយលទ្ធភាពនៃការចម្លងវីរុសនេះនៅក្នុងប្រទេស ក៏នៅតែជាក្តីព្រួយបារម្ភនៅឡើយដែរ។ អាស្រ័យហេតុនេះ ក្រសួងសុខាភិបាលសូមអំពាវនាវ និងក្រើនរំលឹកដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ ត្រូវបន្តអនុវត្តការការពារការចម្លងវីរុសកូវីដ-១៩ ដោយបង្កើនការប្រុងប្រយ័ត្នខ្ពស់ក្នុងអំឡុងពិធីបុណ្យភ្ជាន់បិណ្ឌ និងភ្ជុំបិណ្ឌ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី០៣ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២០ ខាងមុខនេះ។ ក្រសួងសូមធ្វើការណែនាំ ដើម្បីអនុវត្តឱ្យបានគ្រប់ៗគ្នានូវវិធានការសំខាន់ៗ ដូចខាងក្រោម៖

១. នៅពេលចូលទៅកាន់ទីវត្តអារ៉ាម ត្រូវពាក់ម៉ាស់ អនុវត្តវិធានការសុវត្ថិភាពបុគ្គល៖

អាជ្ញាធរជាចាំនី-ខេត្ត គណៈបញ្ជាការឯកភាពឃុំ/សង្កាត់/ខណ្ឌ គណៈកម្មការថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់រៀបរៀបរយក្នុងទីវត្តអារ៉ាម និងគណៈកម្មការវត្ត ត្រូវចាត់ចែងណែនាំឱ្យមានការអនុវត្តវិធានការសុខាភិបាល (មានដូចខាងក្រោមនេះ) បង្កើនសកម្មភាពត្រួតពិនិត្យ តាមដាន លើពុទ្ធបរិស័ទ ដែលចេញ-ចូល ទីវត្តអារ៉ាម វិហារ សាលាឆាន់ និងកុដិនីមួយៗឱ្យបានហ្មត់ចត់ ហើយបុគ្គលគ្រប់រូប ត្រូវចូលរួមអនុវត្តកិច្ចការពារខ្លួនកុំឱ្យមានការចម្លងវីរុសកូវីដ-១៩ ដោយអនុវត្តនូវវិធានការ ដូចតទៅ៖

- រៀបចំឱ្យមានកន្លែងលាងដៃនៅច្រកចេញ-ចូល និងរក្សាការលាងសម្អាតដៃ ឱ្យបានញឹកញាប់
- ធ្វើការវាស់កំដៅ និងបាញ់ទឹកអាល់កុលលាងដៃ ឬទឹកដែលលាងដៃ សម្រាប់រាល់ពុទ្ធបរិស័ទទាំងអស់កុំឱ្យមានការច្វេសប្រហែសនៅមុខច្រកចេញ-ចូលក្លោងទ្វារនីមួយៗ
- ចាត់ចែងឱ្យមានមានគម្លាតសុវត្ថិភាពបុគ្គល ដោយមានគម្លាតពីគ្នា យ៉ាងតិចមួយម៉ែត្រកន្លះ (១.៥ម៉ែត្រ) គ្រប់ពេលដែលពុទ្ធបរិស័ទចូលក្នុងទីវត្តអារ៉ាម វិហារ សាលាឆាន់ និងកុដិ នីមួយៗ
- ចាត់ចែងឱ្យមានការរក្សាគម្លាតពីគ្នា យ៉ាងតិចមួយម៉ែត្រកន្លះ (១.៥ម៉ែត្រ) ក្នុងពេលមានការប្រគេនចង្ហាន់ បច្ច័យ និងគ្រឿងឧបភោគបរិភោគ ដល់ព្រះសង្ឃ ឬនៅពេលអង្គុយ ឬឈរចាំការប្រគេន ឬវេចង្ហាន់ និងទេយ្យទាន ឬពេលស្តាប់ព្រះធម៌
- ព្រះសង្ឃគ្រប់ព្រះអង្គ ជូនដី តាជី និងពុទ្ធបរិស័ទទាំងអស់ ត្រូវពាក់ម៉ាស់គ្រប់ៗគ្នា នៅពេលចូលក្នុងទីវត្តអារ៉ាម ពេលអង្គុយ ឬឈរចាំការប្រគេន ឬវេចង្ហាន់ និងទេយ្យទាននានា ជាពិសេសនៅពេលសូត្រព្រះធម៌ ពេលបង្សុកូល និងឧទ្ទិសកុសលជូនដល់មាតា បិតា ញាតិការ និងបុព្វការីជន ដែលបានធ្វើមរណកាលទៅហើយនោះ
- ពិនិត្យតាមដានពុទ្ធបរិស័ទទាំងអស់ និងរាយការណ៍មកទូរស័ព្ទទាន់ហេតុការណ៍ ១១៥ នូវរាល់ការណីសង្ស័យឆ្លងជំងឺកូវីដ-១៩ ឬករណីគ្រុនក្តៅ ឬគ្រុនផ្តាសាយដែលកើតមានជាក្រុម
- អាជ្ញាធរខេត្ត ស្រុក ក្រុង ខណ្ឌ រដ្ឋបាលឃុំ/សង្កាត់ ត្រូវចាត់តាំងកម្លាំងគ្រប់គ្រង ឃ្លាំមើល និងធ្វើការណែនាំការអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការការពារការចម្លងជំងឺកូវីដ-១៩ និងការរៀបចំទុកជាក់ម្ហូបអាហារឱ្យបានល្អ កុំច្របូកច្របល់គ្នាធ្វើសវាងការពុលចំណីអាហារ ឬជំងឺបណ្តាលមកពីចំណីអាហារមិនមានសុវត្ថិភាព ព្រមទាំងជំរុញលើកទឹកចិត្តប្រជាជនក្នុងដែនសមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន ឱ្យមានការអនុវត្តនូវិធានការការពារខ្លួនស្របតាមរបៀបនៃ *ការរស់នៅថ្មីភា*

ទីស្តីការក្រសួងសុខាភិបាល ទីតាំងលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៨៥-២៣) ៨៨៥ ៥៧០ / ៨៨៤ ៥០៩

តាមវិធានថ្មី ក្នុងបរិបទប្រឈមនឹងជំងឺកូវីដ-១៩ ដោយប្រកាន់យកនូវការអនុវត្តអនាម័យដៃស្អាត (លាងដៃឱ្យញឹកញាប់) ពាក់ម៉ាស់ (ក្នុងករណីចាំបាច់) ប្រើក្រម៉ា ឬក្រដាសជូតមាត់ ខ្ទប់មាត់ពេលមានក្អកកណ្តាស់ និងអនុវត្តគម្លាតសុវត្ថិភាពសង្គម និងគម្លាតសុវត្ថិភាពបុគ្គល ជាចាំបាច់។

២. ជ្រើសរើសការជួបជុំគ្រួសារ ឬជំណើរកំសាន្តប្រកបដោយសុខត្ថភាពមិនមានការចម្លងជំងឺ ៖

- ជ្រើសរើសដំណើរកំសាន្តជាច់ដោយឡែក ជាលក្ខណៈគ្រួសារដែលមិនមានការជួបជុំគ្នាច្រើន ដូចជាការដើរកំសាន្តជាគ្រួសារ នៅតាមរមណីយដ្ឋាន ឬទីកន្លែងកំសាន្ត ដែលមានបរិយាកាសល្អ មានខ្យល់ចេញចូលល្អគ្រប់គ្រាន់ មិនស្ថិតនៅក្នុងទីដែលបិទជិតគ្មានខ្យល់ចេញចូល និងប្រើម៉ាស៊ីនត្រជាក់ច្រើន
- កាត់បន្ថយឱ្យបានជាអតិបរមា នូវការជួបជុំគ្នាដែលមានមនុស្សច្រើនដូចជា ការធ្វើដំណើរកំសាន្ត ប្រមូលផ្តុំច្រើន បរិភោគអាហារជាមួយមិត្តភក្តិច្រើនខាងក្រៅផ្ទះ ការជប់លៀងទ្រង់ទ្រាយធំជាដើម
- ជៀសវាងការជួបជុំគ្នាលេងល្បែងស៊ីសង ការច្រៀងរាំ ដែលមិនមានគម្លាតសុវត្ថិភាព ឬការជួបជុំគ្នាស៊ីផឹកគ្រឹកគគ្រេងនិងចៀសវាងការសេពគ្រឿងស្រវឹងច្រើន ព្រមទាំងត្រូវជៀសវាងការប្រើប្រាស់គ្រឿងញៀន ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាព និងអាចជាកត្តាហានិភ័យខ្ពស់ក្នុងការចម្លង ឬកើតរោគផងដែរ
- ជៀសវាងកន្លែងកំសាន្តនៅតាមបែបជារង្គសាល ខារ៉ាអូខេ ឬក្លឹបកំសាន្តនានា ដែលប្រមូលផ្តុំគ្នាច្រើន និងមានហានិភ័យនៃការចម្លងវីរុសកូវីដ-១៩ និងដែលមិនមានការអនុញ្ញាតឲ្យបើកដំណើរការនោះឡើយ។

៣. ជ្រើសរើសមធ្យោបាយធ្វើដំណើរមានសុខត្ថភាព កាត់បន្ថយជាអតិបរមានូវការចម្លងជំងឺ និងចៀសវាងគ្រោះថ្នាក់ចរាចរ ៖

- ជៀសវាងប្រើប្រាស់មធ្យោបាយសាធារណៈដែលមានផ្ទុកមនុស្សច្រើន
- បើចាំបាច់ត្រូវធ្វើដំណើរតាមមធ្យោបាយសាធារណៈ លោកអ្នកត្រូវពាក់ម៉ាស់ជានិច្ច រក្សាគម្លាតសុវត្ថិភាពបុគ្គល និងត្រូវយកតាមខ្លួននូវទឹកអាល់កុល ឬទឹកដែលសម្រាប់លាងដៃ
- ជៀសវាងការធ្វើដំណើរ ប្រសិនបើមានអាការៈក្តៅខ្លួន ក្អក ឬពិបាកដកដង្ហើម ឬមានបញ្ហាសុខភាព
- សម្រាប់អ្នកបើកបរត្រូវ ៖
    - បើកបង្អួចរថយន្ត ឲ្យមានខ្យល់ចេញចូល ជៀសវាងប្រើម៉ាស៊ីនត្រជាក់ច្រើនពេក
    - លើកទឹកចិត្តឲ្យអ្នកដំណើរពាក់ម៉ាស់ ឬក្រម៉ាខ្ទប់មាត់ និងច្រមុះ ដើម្បីជៀសវាងការចម្លងជាយថាហេតុនៃវីរុសផ្កាសាយផ្សេងៗ រួមទាំងវីរុសកូវីដ-១៩ ផងដែរ
    - ត្រូវសម្អាតរថយន្តជាប្រចាំដោយប្រើទឹកសាប៊ូ ជូតអាល់កុលនៅតាមឆ្នាក់កៅអី និងកន្លែងដែលមនុស្សបានប៉ះពាល់
    - ម្ចាស់រថយន្តត្រូវមានទឹកអាល់កុល ឬអាល់កុលដែលលាងដៃ ឲ្យអ្នកដំណើរលាងដៃ មុនពេលឡើងលើរថយន្ត
    - ចំពោះអ្នកបើកបររថយន្ត បើមានរោគសញ្ញា ដូចជាគ្រុនក្តៅ ផ្តាសាយ ឈឺបំពង់ក ពិបាកដកដង្ហើមជាដើម ត្រូវផ្អាកការបើកបរជាបណ្តោះអាសន្ន រួចទៅមន្ទីរពេទ្យវិញ ដើម្បីត្រួតពិនិត្យសុខភាព។ អ្នកបើកបរមានហានិភ័យខ្ពស់ ដោយសារការជួបជាមួយមនុស្សច្រើន ដូច្នេះ ត្រូវចេះការពារខ្លួនពីការចម្លងវីរុសកូវីដ-១៩ និងមេរោគផ្សេងៗ
    - ប្រកាន់ខ្ជាប់នូវច្បាប់ចរាចរ នៅពេលបើកឃ្លៀ ជៀសវាងគ្រោះថ្នាក់ចរាចរ ដែលអាចកើតមានជាយថាហេតុដោយសារការបើកបរលឿនពេក ឬបើកបរមិនមានសុវត្ថិភាព។

៤. ជ្រើសរើសទីកន្លែងស្នាក់នៅប្រកបដោយសុខត្ថភាពកាត់បន្ថយហានិភ័យនៃការចម្លងជំងឺ

- ជ្រើសរើសសណ្ឋាគារ ឬផ្ទះសំណាក់ ដែលអនុវត្តវិធានការការពារ និងអនាម័យល្អ តាមការណែនាំរបស់ក្រសួងសុខាភិបាល ដូចជាមានដាក់ទឹកស្អាត និងសាប៊ូ ឬទឹកអាល់កុល ឬអាល់កុលដែល សម្រាប់លាងសំអាតដៃ និងធ្វើអនាម័យបន្ទប់ ព្រមទាំងមានការសម្អាតសម្ភារៈប្រើប្រាស់ក្នុងបន្ទប់បានត្រឹមត្រូវ
- ប្រើប្រាស់បន្ទប់ស្នាក់នៅ ដែលមានបង្អួចបើកបាន សម្រាប់ឲ្យខ្យល់ចេញចូលបានល្អ កាត់បន្ថយជាអតិបរមានូវការប្រើប្រាស់ម៉ាស៊ីនត្រជាក់ ឬអាចប្រើកង្ហា

- ម្ចាស់សណ្ឋាគារ ឬផ្ទះសំណាក់៖
  - ត្រូវសម្អាត និងសម្លាប់មេរោគនៅក្នុងសណ្ឋាគារ ឬផ្ទះសំណាក់របស់ខ្លួនឲ្យបានត្រឹមត្រូវ ដូចជាបន្ទប់ទឹក បន្ទប់ធំ ផ្លូវដើរ បង្គាន់ដៃជណ្តើរ ជណ្តើរយន្ត ប៊ូតុងចុចជណ្តើរយន្ត បង្គាន់ដៃទ្វារ កុងតាក់ភ្លើង និង សម្ភារៈប្រើប្រាស់ផ្សេងៗ ក្នុងបន្ទប់ភ្ញៀវជាដើម
  - ត្រូវមានគម្លាតសុវត្ថិភាពបុគ្គល នៅកន្លែងឆែកចូលយកបន្ទប់សម្រាក និងកន្លែងបង់ប្រាក់ ដោយត្រូវមានដាក់គំនូសសម្គាល់ សម្រាប់តម្រង់ជួរឈរចាំឲ្យមានគម្លាតពីបុគ្គលម្នាក់ទៅម្នាក់ មួយម៉ែត្រកន្លះឡើង
  - បន្ទប់ទឹក ត្រូវមានសាប៊ូជាប់ជាប្រចាំ សម្រាប់អតិថិជនប្រើប្រាស់សម្រាប់លាងដៃ ក្នុងអំឡុងពេលស្នាក់នៅរបស់អតិថិជន
  - ត្រូវតែអនុវត្តវិធានការការពារនៅទីតាំងរបស់ខ្លួន ដើម្បីជៀសវាងការចម្លងវីរុសកូវីដ-១៩ ឬចម្លងជំងឺពីអតិថិជនមួយទៅអតិថិជនម្នាក់ ឬច្រើននាក់។

៥. ជ្រើសរើសកាន់តួលានអសារគ្រប់បជាយសុខត្ថភាពមិនបង្កការចម្លងជំងឺ ឬការពុលចំណីអាហារ៖

- ត្រូវអនុវត្តនូវគោលការណ៍សុវត្ថិភាពចំណីអាហារល្អ ដោយចម្អិនម្ហូបអាហារឲ្យបានឆ្អិនល្អ រក្សាចំណីអាហារឲ្យដាច់ពីគ្នាពីមុខម្ហូបមួយទៅមុខម្ហូបមួយទៀត កុំដាក់ចូលច្របូកច្របល់គ្នា ដែលអាចងាយនឹងផ្ទុម និងមានភាពងាយស្រួលក្នុងការបង្កមេរោគ ដោយសារពពួកផ្សិត ឬមានមេរោគ បាក់តេរី ជាដើម។
- រក្សាអនាម័យចំណីអាហារ ដូចជាបរិភោគអាហារឆ្អិនល្អ ទុកដាក់អាហារឆៅ និងឆ្អិនដាច់ដោយឡែកពីគ្នា ទុកដាក់អាហារក្នុងសីតុណ្ហភាពសុវត្ថិភាព និងប្រើប្រាស់ទឹកស្អាត និងវត្ថុធាតុដើមល្អ សម្រាប់ចម្អិនអាហារជាដើម
- ម្ចាស់ និងបុគ្គលិកបម្រើការនៅតាមភោជនីយដ្ឋាន អាហារដ្ឋាន ហាងកាហ្វេ និងហាងលក់អាហារ ត្រូវធ្វើអនាម័យខ្លួនឯង លាងសម្អាតដៃ និងអនាម័យផ្លូវដង្ហើមជាទៀងទាត់ ដូចជាពាក់ម៉ាស់ឲ្យបានត្រឹមត្រូវជានិច្ច ក្នុងពេលបម្រើអតិថិជន និងក្នុងពេលចាំបាច់
- ម្ចាស់ភោជនីយដ្ឋាន អាហារដ្ឋាន ហាងកាហ្វេ និងហាងលក់អាហារ ត្រូវរៀបចំឲ្យមានកន្លែងលាងដៃ និងលើកទឹកចិត្តអតិថិជនដែលចូលមកកន្លែងរបស់ខ្លួន ឲ្យលាងដៃរបស់ពួកគាត់ ជាមួយសាប៊ូ និងទឹកស្អាត ឬជាមួយទឹកអាល់កុល ឬអាល់កុលជែល សម្រាប់លាងដៃ ដែលមានដាក់នៅតាមច្រកចូលទៅកាន់ទីកន្លែងរបស់ខ្លួន
- រៀបចំតុ និងកៅអីអង្គុយ ព្រមទាំងត្រូវណែនាំភ្ញៀវឱ្យរក្សាគម្លាតសុវត្ថិភាពរវាងភ្ញៀវម្នាក់ទៅភ្ញៀវម្នាក់ទៀត ចម្ងាយមួយម៉ែត្រកន្លះឡើង
- ចំពោះភោជនីយដ្ឋានដែលមានអាហារប៊ូហ្វេ ត្រូវប្តូរឧបករណ៍ចាប់ម្ហូបឲ្យបានញឹកញាប់ និងត្រូវសម្អាតទឹកន្លែងដាក់ម្ហូបជានិច្ច បន្ទាប់ពីភ្ញៀវបានប្រើរួច។ ជូតសម្អាតម៉ាស៊ីនឆុងការហ្វេ និងម៉ាស៊ីនកេសជ្ជៈញឹកញាប់ បន្ទាប់ពីភ្ញៀវម្នាក់ៗប្រើរួច។
- អ្នកបម្រើក្នុងភោជនីយដ្ឋាន អាហារដ្ឋាន ហាងកាហ្វេ និងហាងលក់អាហារ ទាំងអស់ ត្រូវតែពាក់ម៉ាស់ជានិច្ច និងរាល់ពេលបម្រើអតិថិជន។
- ត្រូវតែសម្អាតតុ និងកៅអី ដែលភ្ញៀវបានក្រោកចេញឲ្យបានត្រឹមត្រូវ ដោយអាល់កុល មុននឹងអនុញ្ញាតឲ្យភ្ញៀវបន្ទាប់ចូលអង្គុយ។
- ក្នុងបន្ទប់ទឹកត្រូវមានសាប៊ូជាប់ជាប្រចាំ សម្រាប់អតិថិជនប្រើប្រាស់សម្រាប់លាងដៃ ពេលប្រើប្រាស់បង្គន់មុនពេល និងក្រោយពេលបរិភោគអាហាររួច។
- សម្ភារប្រើប្រាស់ ចាន ស្លាបព្រា កែវទឹកកម្រាលតុ ឬកន្សែង និងវត្ថុប្រើប្រាស់ផ្សេងៗត្រូវតែលាងសំអាតឲ្យបានត្រឹមត្រូវ មុនដាក់ឲ្យអតិថិជនប្រើប្រាស់
- មិនត្រូវចូលទៅប្រជុំគ្នា ឬទាំគ្នាបរិភោគអាហារជុំគ្នា នៅទីកន្លែងមិនមានសុវត្ថិភាព និងដែលអាចជាកន្លែងមានការងាយស្រួលក្នុងការចម្លងវីរុសកូវីដ១៩ ឬចម្លងរោគផ្សេងៗ ដូចជាកន្លែងដែលមានការស្រែកហ៊ោកញ្ជៀវ ឬបន្ទប់ដែលបិទជិតងងឹតៗមិនមានខ្យល់ចេញចូលបានល្អជាដើម។

៦. បុគ្គលម្នាក់ៗ ត្រូវរក្សាអនាម័យជានិច្ច

- ត្រូវលាងដៃឲ្យបានញឹកញាប់ជាមួយសាប៊ូ និងទឹកស្អាត ទឹកអាល់កុលលាងដៃ ឬទឹកអាល់កុលជែល ឲ្យបានញឹកញាប់ និងជាប្រចាំ។

143

- ក្រវ៉ែនប់ម៉ាត់ និងច្រមុះ នៅពេលក្អក កណ្តាស់ ដោយប្រើម៉ាស់ ក្រម៉ា កន្សែង ឬក្រដាសអនាម័យ រួចទម្លាប់បោះចោលក្នុងធុងសំរាមបិទជិត
- ពាក់ម៉ាស់ នៅពេលចាំបាច់ ជាពិសេសត្រូវពាក់ម៉ាស់ជាប់ជានិច្ចនៅពេលបុគ្គលធ្វើដំណើរចេញក្រៅ និងមានការជួបមុខមនុស្សម្នាផ្សេងៗ
- ក្រវ៉ែជៀសវាងការខាកស្តោះពាសវាលពាសកាល។

៧. ត្រូវរក្សាគម្លាតសុខភាពបុគ្គល

- ក្រវ៉ែរក្សាគម្លាតសុវត្ថិភាពពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត យ៉ាងតិចមួយម៉ែត្រកន្លះ នៅពេលឈរ អង្គុយ ឈរអង់ចាំ ឈរជជែកគ្នា ឬនៅទីកន្លែងផ្សេងៗ ដូចជាទីវត្តអារ៉ាម កន្លែងសាធារណៈ ភោជនីយដ្ឋាន អាហារដ្ឋាន ទីកន្លែងកំសាន្តលំហែកាយ ឬទីកន្លែងទេសចរនានា
- អ្នកដែលមានហានិភ័យខ្ពស់នៃការចម្លងជំងឺ ដូចជាជនចាស់ជរា ជនដែលមានជំងឺប្រចាំកាយ ស្ត្រីមានផ្ទៃពោះ និងកុមារតូចៗជាដើម មិនត្រូវចូលរួមដំណើរ ជួបជុំគ្នាច្រើន ឬបើមានការចាំបាច់បំផុតនោះ ត្រូវតែមានការអនុវត្តន៍កិច្ចការពារខ្លួនឲ្យបានល្អ និងរក្សាគម្លាតពីគ្នា ព្រមទាំងមានអ្នកជួយមើលការខុសត្រូវឲ្យបានត្រឹមត្រូវ ព្រមទាំងអនុវត្តវិធានការដូចបានជម្រាបជូនខាងលើនេះ។

ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះការយកចិត្តទុកដាក់ចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ និងការថែរក្សាសុខភាព របស់បងប្អូនប្រជាពលរដ្ឋទាំងអស់ ហើយក្រសួងក៏សូមអំពាវនាវដល់សាធារណជនទាំងអស់ សូមចូលរួមអនុវត្តតាមការណែនាំខាងលើនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីរួមចំណែកកាត់ផ្តាច់ការចម្លងវីរុសកូវីដ-១៩ ពីបុគ្គលម្នាក់ទៅម្នាក់ និងកុំឲ្យមានការចម្លងវីរុសកូវីដ-១៩ នេះចូលក្នុងសហគមន៍យើង។

ប្រសិនបើបងប្អូនប្រជាពលរដ្ឋមានបញ្ហាសុខភាព ឬមានជំងឺ ឬសង្ស័យថាមាការឆ្លងជំងឺ សូមប្រញាប់ទៅស្វែងរកការពិនិត្យពិគ្រោះនៅមន្ទីរពេទ្យរដ្ឋ ឬទំនាក់ទំនងតាមលេខផ្តល់ជូនខាងក្រោមនេះ។

ក្រសួងសុខាភិបាល និងបន្តធ្វើការជូនដំណឹងដល់សាធារណជន អំពីការវិវត្តន៍នៃបញ្ហាសុខភាពតាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួងសុខាភិបាល www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារអប់រំសុខភាព ដែលអាចទាញយកមកមើល និងប្រើប្រាស់បាន។ សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងលេខទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៨២៤ ឬ ០១២ ៨៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨។

ថ្ងៃ ៩ ទ្រី ១៣ កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២០

រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជា
ប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩

ម៉ម ប៊ុនហេង

ទីតាំងទទួលៈ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ឧត្តមក្រឡាធិការដ្ឋាន
-ក្រសួងមហាផ្ទៃ
-ក្រសួងទេសចរណ៍
-ក្រសួងធម្មការ និងសាសនា
-រដ្ឋបាលរាជធានី-ខេត្ត
-ឯកសារ-កាលប្បវត្តិ